# បទវិន័យ សំរាប់ ភ្នាក់ងារ ទទួលបន្ទុក ផ្នែកប្រតិបត្តិ ច្បាប់

Code of Conduct for Law Enforcement Officials

*អនុម័តដោយសេចក្តីសំរេច របស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃទី ១៧ ខែ ធ្នូ ១៩៧៩ ។*

Adopted by by General Assembly resolution 34/169 of 17 December 1979.

*ច្បាប់ទូន្មាននេះបានចែងថា ជនដែលអនុវត្ត ឬប្រើប្រាស់ច្បាប់ប៉ូលីសដូចជាភ្នាក់ងារតម្រួត ជា ដើម ត្រូវតែគោរពនិងរក្សាការពារចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ លើកដំកើង និង គោរពតាម មាគ៌ាសិទ្ធិមនុស្ស ដែលគេបានចែងនៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ១០៦ របស់ អង្គការសហប្រជាជាតិ កាលពីថ្ងៃ ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩ ។*

*មហាសន្និបាតបានទទូចស្នើដល់គ្រប់រដ្ឋាភិបាល ឲ្យយកច្បាប់ទូន្មាន (ឬបទវិន័យ) នេះ ទៅប្រើ ក្នុងគំរោងការនានារបស់ជាតិខ្លួន ក្នុងវិស័យច្បាប់នីតិបញ្ញត្តិនិងនីតិប្រតិបត្តិ។ ច្បាប់ទូន្មាន នេះ ត្រូវចាត់ ជាគោលសំខាន់បំផុតសំរាប់អោយភ្នាក់ងារតម្រួតគ្រប់ប្រភេទគោរពតាម ។*

*សេចក្តីសំរេចចិត្តរបស់មហាសន្និបាត ដែលបានបង្កើតច្បាប់ទូន្មាននេះឡើងបានចែងថា លក្ខណៈ ធម្មជាតិនៃមុខងាររបស់ក្រសួងដែលទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ក្នុងវិស័យរក្សា ការពាររបៀបរៀបរយសាធារណៈ និងបែបបទនៃការបំពេញមុខងារនេះ អាចមានឥទ្ធិពលផ្ទាល់ទៅ លើគុណភាពនៃ ជីវិតមនុស្សគ្រប់ៗគ្នាផង និងសង្គមមនុស្សជាទូទៅផង។ មហាសន្និបាតបាន ពោលបញ្ជាក់ថាត្រូវតែចងចាំជានិច្ចនូវសារៈសំខាន់របស់បេសកកម្មនេះ ពោលគឺភ្នាក់ងារដែល ទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវតែបំពេញភារកិច្ចខ្លួនដោយយកចិត្តទុកដាក់ ហើយប្រកប ដោយសេចក្តីថ្លៃថ្នូរផង។ ប៉ុន្តែទោះជា យ៉ាងណាក៏ដោយ ក៏គេដឹងច្បាស់ថា នៅក្នុងការបំពេញ បេសកកម្មខ្លះៗ ដូចចែងខាងលើនេះ មុខជាមាន ការរំលោភបំពានលើសិទ្ធិជាមិនខាន ។*

*ក្រៅអំពីការដាស់តឿនឲ្យភ្នាក់ងារទាំងអស់នោះលើកដំកើង និងគោរពសិទ្ធិមនុស្ស, បទវិន័យ ដែលជាច្បាប់មួយក្នុងចំណោមច្បាប់ជាច្រើនទៀត, បានហាមប្រាមជាដាច់ខាតមិនឲ្យ មានការធ្វើទារុណ កម្ម។ ការប្រើកំលាំងបាយក៏ត្រូវហាមឃាត់ដែរ លើកលែងតែនៅក្នុង កាលៈទេសៈជាចាំបាច់ខ្លះ ដែលគេ ត្រូវប្រើកំលាំងដោយខានពុំបាន។ ច្បាប់ទូន្មាននេះតំរូវអោយ មានការថែរក្សាសុខភាពយ៉ាងពេញលេញ ចំពោះជនដែលជាប់ក្នុងមន្ទីរឃុំឃាំង ។*


*រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល*

មាត្រានីមួយៗនៃមាត្រាទាំង ៨ ខាងក្រោមនេះ សុទ្ធតែមានអត្ថាធិប្បាយបំភ្លឺ ដើម្បីជួយសំរួល ដល់ការប្រើប្រាស់ច្បាប់នេះនៅក្នុងអង្គភាពជាតិផ្នែកនីតិបញ្ញត្តិ (ក្រុមអ្នកចងក្រងច្បាប់) និងផ្នែកនីតិប្រតិបត្តិ (ក្រុមអ្នកអនុវត្តន៍ច្បាប់) ។

**តទៅនេះគឺជាអត្ថបទស្តីពីបទវិន័យ ៖**

## មាត្រា ១

ក្នុងការបំរើសហគមន៍ និងក្នុងការការពារប្រជាពលរដ្ឋកុំឲ្យមានការប្រព្រឹត្តខុសច្បាប់ ភ្នាក់ងារ តម្រួតគ្រប់ប្រភេទត្រូវបំពេញភារកិច្ចរបស់ខ្លួនឲ្យត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា។ វិជ្ជាជីវៈបែបនេះ តម្រូវឲ្យភ្នាក់ងារទាំងអស់ប្រកាន់ជាប់ជានិច្ចនូវការទទួលខុសត្រូវក្នុងកំរិតដ៏ខ្ពស់បំផុត ។

អត្ថាធិប្បាយ ៖

ក-ពាក្យថា “ភ្នាក់ងារទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់” បានន័យថា ភ្នាក់ងាររដ្ឋការដែលបំរើក្នុងក្រសួងនានាដែលទាក់ទងដល់ការចាប់ចង ឬឃុំឃាំង ដូចជាក្រសួងប៉ូលីសជាដើម។ ភ្នាក់ងារ ទាំងនោះ គឺជាភ្នាក់ងារដែលបានត្រូវគេតែងតាំង និងបោះឆ្នោតជ្រើសរើស។

ខ-ពាក្យថា “ភ្នាក់ងារទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់” ត្រូវរាប់បញ្ចូលទាំងពលទាហាន ហើយនិងភ្នាក់ងារក្រសួងសន្តិសុខជាតិផងដែរ ចំពោះប្រទេសទាំងឡាយណាដែលប្រើកំលាំងទ័ព ឬកង សន្តិសុខជាតិជំនួសកងតម្រួត (ប៉ូលីស)។

គ-ក្នុងការបំរើសហគមន៍ គេត្រូវរាប់បញ្ចូលជាពិសេសនូវភារកិច្ច ដែលអាចជួយដល់សមាជិកសហគមន៍នានាដែលត្រូវការជំនួយជាបន្ទាន់។ គេត្រូវតែបំរើផលប្រយោជន៍សហគមន៍ ទោះដោយ មូលហេតុផ្ទាល់ខ្លួនក្តី មូលហេតុសេដ្ឋកិច្ចក្តី សង្គមកិច្ចក្តី ឬក្នុងភាពអាសន្នផ្សេងៗក្តី ។

ឃ-ច្បាប់បញ្ញាត្តិនេះជាបំរាមដល់ភ្នាក់ងារតំរួត មិនឲ្យប្រព្រឹត្តអំពើណាដែលសាហាវឃោរឃៅ (យ៉ាងបែបព្រៃផ្សៃ) ឬដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកទោស ឬជនជាប់ចោទ ។ លើសពីនេះទៅទៀត តំរួតត្រូវគោរពវិន័យឲ្យបានប្រាកដប្រជា ក្នុងការបំពេញបេសកកម្មទាំងឡាយណា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់ព្រហ្មទណ្ឌ (ច្បាប់សំរាប់ធ្វើទោស


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដល់ជនដែលប្រព្រឹត្តល្មើសនឹង ច្បាប់រដ្ឋ) ទាំងមូល។ រីឯភ្នាក់ងារតំរួតណាដែលពុំមានលទ្ធភាពអាចប្រព្រឹត្តអំពើឃោរឃៅនេះបាន ក៏ ត្រូវតែគោរពតាមបទវិន័យនេះឲ្យបានដិតដល់ដែរ ។

## មាត្រា ២

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ភ្នាក់ងារតំរួតត្រូវគោរពព្រមទាំងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ។ ក្នុងពេលជាមួយគ្នានោះ គេត្រូវខំថែរក្សានិងលើកដំកើងសិទ្ធិមនុស្សទាំងអស់គ្នា ។

អត្ថាធិប្បាយ ៖

ក-សិទ្ធិមនុស្សដូចចែងក្នុងមាត្រាខាងលើ បានត្រូវច្បាប់ជាតិ និងអន្តរជាតិកត់សំគាល់និង ការពារយ៉ាងខ្ជាប់ខ្ជួន។ ក្នុងចំណោមច្បាប់អន្តរជាតិទាំងឡាយដែលទាក់ទងដល់វិស័យសិទ្ធិមនុស្សនេះមាន ជាអាទិ៍គឺ “ការប្រកាសសិទ្ធិមនុស្សជាសកល” , “សិទ្ធិសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិក្នុង វិស័យនយោបាយ” , “សេចក្តីប្រកាសអំពីកិច្ចការពារមនុស្សគ្រប់រូប ដើម្បីកុំឲ្យមានទារុណកម្មទណ្ឌកម្ម ឬការធ្វើទុក្ខបុកម្នេញដ៏សាហាវឃោរឃៅ ឬអមនុស្សធម៌”, “សេចក្តីប្រកាសនៃសហប្រជាជាតិស្តីអំពី ការបំបាត់ចោលនូវ ការប្រកាន់ពូជសាសន៍គ្រប់ប្រភេទ”, “មហាសន្និបាតអន្តរជាតិស្តីអំពីការបំបាត់ ចោលនូវការប្រកាន់ពូជសាសន៍គ្រប់ប្រភេទ” , “មហាសន្និបាតអន្តរជាតិស្តីអំពីការហាមឃាត់ និងការ ដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មនៃពួកអាប៉ាថាយ្យ”, “មហាសន្និបាតស្តីអំពីសេចក្តីបង្ការ ហើយនិងការ ដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មនៃការកាប់សម្លាប់រង្គាលប្រល័យពូជសាសន៍”, “វិន័យនិងបទបញ្ជាចាំបាច់ សំរាប់គ្រប់គ្រងអ្នកទោស” ហើយនិងមាន “សន្និបាតនៅទីក្រុងវីយ៉ែណាស្តីអំពីទាំនក់ទំនងខាងផ្នែកកុង ស៊ុល (តំណាងក្រសួងការបរទេស) ដែលនៅក្រៅប្រទេស” ។

ខ-ក្នុងការផ្សាយជាសាធារណៈស្តីអំពីច្បាប់ដែលចែងក្នុងមាត្រា ២ ខាងលើ, ទោះបីតាមរយៈសារពតិមាន, សៀវភៅ, ទស្សនាវដ្តី ឬតាមវិទ្យុ ទូរទស្សន៍ក្តី ជាការចាំបាច់ត្រូវតែរំឭកអំពីច្បាប់ ប្រចាំតំបន់ ឬរដ្ឋផ្សេងៗដែលចង្អុលបង្ហាញ ហើយនិងការពារសិទ្ធិទាំងឡាយនេះ ។

## មាត្រា ៣

ភ្នាក់ងារតំរួតអាចប្រើកំលាំងបានតែនៅកាលៈទេសៈណាដែលចាំបាច់បំផុត។ ហើយការប្រើកំ លាំងនេះ ត្រូវកំរិតត្រឹមតែក្នុងរង្វង់នៃការបំពេញបេសកកម្មតែប៉ុណ្ណោះ ។

អត្ថាធិប្បាយ ៖


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ក-ច្បាប់ដែលចែងក្នុងមាត្រាខាងលើ បញ្ជាក់អំពីការប្រើកំលាំងពីសំណាក់ភ្នាក់ងារតំរួត។ ការប្រើកំលាំងបែបនេះ មិនត្រូវយកទៅប្រើនៅក្នុងពេលធម្មតាទេ ពោលគឺភ្នាក់ងារតំរួតអាចប្រើកំលាំងបានតែក្នុងករណីណាដែលមានការចាំបាច់បំផុត ជាពិសេសគឺក្នុងការបង្ការកុំឲ្យមានអំពើឧក្រិដ្ឋ ឬ ក្នុងការចាប់ចងជនឧក្រិដ្ឋ ឬជនដែលគេសង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្ម។ ហាមផ្តាច់មិនឲ្យប្រើកំលាំង ហួសព្រំដែន ។

ខ-តាមធម្មតា ច្បាប់របស់ប្រទេសនិមួយៗ បានដាក់កំរិតល័ក្ខខ័ណ្ឌយ៉ាងម៉ឺងម៉ាត់ទៅលើការ ប្រើកំលាំងនេះ។ ភ្នាក់ងារតំរួតអាចប្រើកំលាំងតិចឬច្រើន អាចអាស្រ័យទៅលើទំហំការដែលត្រូវ ប្រតិបត្តិ។ ក្នុងការបកស្រាយអំពីច្បាប់នៅក្នុងមាត្រា៣ខាងលើនេះ គេយល់ថាត្រូវតែគោរពទៅតាម គោលការណ៍ប្រតិបត្តិ ដែលយោលទៅលើទំហំការ។ ទោះជាក្នុងករណីណាក៏ដោយ គេមិនត្រូវយក ច្បាប់នៃមាត្រា ៣ នេះ ទៅបកស្រាយជាលេស ដើម្បីអនុញ្ញាតឲ្យមានការប្រើកំលាំង ក្នុងគោលដៅណា មួយដែលហួសអំពីកំរិតដែលច្បាប់បានចែងឡើយ ។

គ-ការប្រើប្រាស់អាវុធ ត្រូវចាត់ទុកថាជាវិធានការណ៍ដ៏ខ្លាំងក្លាបំផុត។ ក្នុងកិច្ចប្រតិបត្តិការទៅលើពួក (ជនឧក្រិដ្ឋ) ក្មេងៗ គេត្រូវរិះរកគ្រប់មធ្យោបាយ ដើម្បីជៀសវាងកុំឲ្យមានការប្រើអាវុធ។ ជាទូទៅ, ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលមានការតដៃដោយ អាវុធពីសំណាក់ជនជាប់ចោទ ដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណា ដែលវិធានការបច្ចុប្បន្នពុំមានកំលាំងគ្រប់គ្រាន់ ដើម្បីទប់ទល់ជាមួយកំលាំងតដៃរបស់ជនជាប់ចោទ រាល់ពេលណាដែល មានការបាញ់កាំភ្លើងក្នុងកិច្ចប្រតិបត្តិការភ្នាក់ងារតំរួតត្រូវរាយការណ៍ជូនទៅក្រសួង មានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

ប្រសិនបើគ្មានការតម្រូវយ៉ាងចាំបាច់អំពីសំណាក់ក្រសួងយុត្តិធមិ (ក្នុងការស្វែងរកយុត្តិធមិ) ទេ ឬប្រសិនបើកាតព្វកិច្ចមិនបង្ខិតបង្ខំទេនោះ ភ្នាក់ងារតំរួតដែលដឹងរឿងសម្ងាត់នានា ត្រូវតែរក្សាទុក រឿងនោះឲ្យនៅតែជារឿងសម្ងាត់ដដែល ។

អត្ថាធិប្បាយ ៖

តាមលក្ខណៈធម្មជាតិនៃកតព្វកិច្ចរបស់គេ ភ្នាក់ងារតំរួតតែងតែទទួលពតិមាននានា ដែលអាចមានការទាក់ទងដល់ជីវិតរបស់អ្នកដែលផ្តល់ពតិមាននោះ ឬដែលជាកត្តាអាចបណ្តាល


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ឲ្យខូចខាតដល់ ប្រយោជន៍ឬកិត្យានុភាពអ្នកដទៃ។ តំរួតត្រូវមានការប្រុងប្រយ័ត្នជានិច្ចក្នុងការយកពត៌មានប្រភេទ ទាំងនេះទៅប្រើប្រាស់ ពោលគឺត្រូវរក្សាទុកវាឲ្យនៅជាអាថ៌កំបាំងជានិច្ច លើកលែងតែក្នុងកាលៈទេសៈ ណាដែលកាតព្វកិច្ចតំរូវឲ្យ ឬក្នុងភាពដ៏ចាំបាច់ដាច់ខាតដែលគេត្រូវតែលាតត្រដាងដើម្បីរកយុត្តិធម៌ ។ ការយករឿងអាថ៌កំបាំងរបស់គេទៅលាតត្រដាង ដើម្បីបំរើឆន្ទៈអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ ខាតព្រោះវាជាការពុំសមរម្យទាល់តែសោះ ។

## មាត្រា ៥

ភ្នាក់ងារតំរួតមិនត្រូវប្រព្រឹត្តអំពើយង់ឃ្នង មិនត្រូវធ្វើការប្រមាថមើលងាយ មិនត្រូវជិះជាន់សង្កត់សង្កិន ឬមិនត្រូវវាយដំច្រំធាក់ជនដែលជាប់ចោទឡើយ។ ភ្នាក់ងារតំរួតមិនត្រូវយកលេសថាខ្លួន មានបញ្ជាពីចៅហ្វាយនាយ ឬយកលេសថាប្រទេសកំពុងស្ថិតនៅក្នុងកាលៈទេសៈដែលមានសង្គ្រាម ឬ ដែលកំពុងតែប្រឈមមុខជាមួយសង្គ្រាម ឬសន្តិសុខជាតិកំពុងតែកើតចលាចល ឬនយោបាយអន្តរជាតិមានភាពមិននឹងន ឬភាពអាសន្នសាធារណៈ ដើម្បីឆ្លៀតឱកាសដាក់ទណ្ឌកម្ម ឬប្រព្រឹត្តអំពើសាហាវឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ ។

អត្ថាធិប្បាយ ៖

ក-សេចក្តីហាមប្រាមនេះ ជាបញ្ញត្តិរបស់សេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឲ្យមានការធ្វើទារុណកម្ម ហើយនិងអំពើសាហាវឃោរឃៅ យង់ឃ្នង ការប្រមាថមើល ងាយមើលថោកព្រមទាំងការដាក់ទណ្ឌកម្ម។ សេចក្តីប្រកាសនេះ ជាសេចក្តីសំរេចរបស់មហាសន្និបាតនៃ អង្គការសហប្រជាជាតិ ដែលចែងយ៉ាងពិស្តារថា ៖ “អំពើយង់ឃ្នងទាំងឡាយដូចបានថ្លែងក្នុងឃ្លាខាង លើនេះ ត្រូវចាត់ទុកថាជាអំពើដែលបំពារបំពានទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ហើយអ្នកដែល ប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលទោសស្មើគ្នានឹងទោសនៃការបដិសេធពុំព្រមប្រតិបត្តិតាមច្បាប់ទម្លាប់ នានា ដែលចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ហើយត្រូវចាត់ទុកថាបានរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលគេបានថ្លែងនៅក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សជាសាកល ព្រមទាំងបាន រំលោភលើច្បាប់អន្តរជាតិផ្សេងៗទៀតក្នុងវិស័យសិទ្ធិមនុស្សទៀតផង” ។

ខ-សេចក្តីប្រកាសនៃសហប្រជាជាតិ ចាត់ទុកអំពើទាំងឡាយខាងក្រោមនេះជាជាទារុណកម្ម ៖ “ពាក្យទារុណកម្មគឺសំអាងទៅលើអំពើទាំងឡាយណាដែលបណ្តាលឲ្យមានការឈឺ


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ចុកចាប់ខាងផ្លូវកាយ ឬផ្លូវចិត្តដែលភ្នាក់ងាររដ្ឋការប្រើប្រាស់ដោយចេតនាដើម្បីជំរិតបង្ខំសួរចម្លើយ អំពីសាមីខ្លួន ឬអំពីអ្នកដទៃ។ ការធ្វើទារុណកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តកំហុសអ្វីមួយ ឬធ្វើទណ្ឌកម្មទៅលើបុគ្គល ដែលគេគ្រាន់តែសង្ស័យថាបានប្រព្រឹត្តកំហុសអ្វីមួយ ឬការគំរាមកំហែងនានាដែលបណ្តាលឲ្យមានការ ឈឺចាប់ជាដំណាំក៏ចាត់ទុកថាជាទារុណកម្មដែរ។ ចំណែកឯការឈឺចាប់ដែលបណ្តាលមកអំពីការដាក់ ទោសតាមលក្ខ័ណច្បាប់ ដែលស្របទៅតាមលំនាំនៃបទបញ្ញាទូទៅក្នុងការគ្រប់គ្រងពួកអ្នកទោស (នៅក្នុងគុក) គេពុំបានចាត់ទុកថាជាទារុណកម្មទេ” ។

គ-ចំពោះពាក្យថា “ប្រព្រឹត្តកម្ម ឬទណ្ឌកម្មឃោរឃៅ,អមនុស្សធម៌ ឬបន្ទាបបន្ថោក” មហា សន្និបាតពុំទាន់បានឲ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែយើងត្រូវតែបកស្រាយន័យវាឲ្យបានច្បាស់លាស់ ដើម្បីជាការងាយស្រួលក្នុងការការពារយ៉ាងម៉ឺងម៉ាត់ តទល់នឹងការបំពារបំពានសព្វបែបយ៉ាង ទាំងការ រំលោភលើផ្លូវកាយទាំងការរំលោភលើផ្លូវចិត្ត ។

## មាត្រា ៦

ភ្នាក់ងារតំរួតត្រូវឧបត្ថម្ភ និងរក្សាសុខភាពបុគ្គលដែលជាប់ឃុំឃាំងនៅក្នុងបន្ទុករបស់ខ្លួនឲ្យបាន ពេញលេញបរិបូណ៌ ជាពិសេសនៅក្នុងកាលៈទេសៈណាដែលអ្នកជាប់ឃុំមានជម្ងឺដំកាត់ផ្សេងៗ តំរួតត្រូវ តែយកបុគ្គលទាំងអស់នេះទៅឲ្យពេទ្យព្យាបាលភ្លាម ។

អត្ថាធិប្បាយ ៖

ក-“ការព្យាបាលជម្ងឺ” គឺយោលទៅលើការព្យាបាលដោយបុគ្គលិកផ្នែកសុខាភិបាលដោយរួម ទាំងភ្នាក់ងារពេទ្យដែលបានហ្វឹកហ្វឺន និងមានសញ្ញាប័ត្រត្រឹមត្រូវ ហើយនិងពេទ្យសង្គ្រោះ។ ហើយការ ព្យាបាលនេះ ត្រូវធានាអោយមានជានិច្ចជាកាល សំរាប់បំរើសេចក្តីតំរូវការរបស់អ្នកជាប់ឃុំ។

ខ-ប្រសិនបើមានពេទ្យប្រចាំក្រសួង ចូលរួមក្នុងបេសកកម្មជាមួយនិងកងតំរួត ភ្នាក់ងារតំរួតទាំងអស់ ត្រូវតែគោរពតាមសំណូមពររបស់ភ្នាក់ងារពេទ្យនេះក្នុងការសំរេចថាតើអ្នកទោសណាខ្លះ ត្រូវការព្យាបាលឲ្យបានត្រឹមត្រូវពីសំណាក់ពេទ្យដទៃក្រៅអំពីពេទ្យប្រចាំក្រសួងតំរួត ។

គ-ត្រូវចាំឲ្យច្បាស់ថា ជាការចាំបាច់ភ្នាក់ងារតំរួតត្រូវថែរក្សាសុខភាពឲ្យជនដែលរងគ្រោះដោយសារការរំលោភច្បាប់ ឬជនរងគ្រោះដោយគ្រោះថ្នាក់ដែលបណ្តាលមកពីការរំលោភច្បាប់ ។

## មាត្រា ៧


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ភ្នាក់ងារតំរួតទាំងឡាយពុំត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធតតាំងនឹងអំពើពុករលួយនេះឲ្យបានមោះមុត ។

អត្ថាធិប្បាយ ៖

ក-អំពើពុករលួយក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋ ពីសំណាក់អាជ្ញាធរដែរ។ អំពើបែបនេះ ជាអំពើដែលផ្ទុយពីកតព្វកិច្ចរបស់ភ្នាក់ងារតំរួត។ ភ្នាក់ងារតំរួតដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់មក គ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើរដ្ឋាភិបាលពុំអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬ អង្គការរបស់ខ្លួន ។

ខ-អត្ថន័យនៃពាក្យ “អំពើឬបទពុករលួយ” ត្រូវចាត់ទុកថាជាតួសំខាន់មួយ នៅក្នុងច្បាប់របស់រដ្ឋ។ ការរួមគំនិតដោយសហប្រតិបត្តិការក្នុងរឿងសំណូកសូកប៉ាន់ផ្សេងៗ គឺជាបទនៃអំពើពុករលួយ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាមជាភ្នាក់ងារតំរួតបើមានការប្រងើយកន្តើយមិនបង្ក្រាប អំពើសូកប៉ាន់ឲ្យបានច្បាស់លាស់ទេ ភ្នាក់ងារតំរួតត្រូវចាត់ទុកថាបានប្រព្រឹត្តឃុបឃិតក្នុងបទពុករលួយ ដែរ។ ការទទួលអំណោយ (ជាវត្ថុឬប្រាជ្ញាបាក់) គ្រឿងលើកទឹកចិត្តផ្សេងៗ កិច្ចសន្យានានា ដែលពុំសម ស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទពុករលួយ ។

គ-ពាក្យថា “អំពើពុករលួយ” ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវ ឆន្ទៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨

ភ្នាក់ងារតំរួត (និងភ្នាក់ងារក្រសួងឯទៀតដែលទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់) គ្រប់ប្រភេទ ត្រូវតែគោរពតាមច្បាប់ហើយនិងបទវិន័យទាំងនេះ។ ហើយគេត្រូវបង្ការ ឬប្រឆាំងអោយបានមោះមុត បំផុតនូវអំពើទាំងឡាយណាដែលបំពាន ឬប៉ះពាល់ដល់ច្បាប់និងបទវិន័យទាំងនេះ។ ភ្នាក់ងារតំរួតដែល ដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពី រឿងនេះទៅអាជ្ញាធរថ្នាក់លើ ឬបើមានការចាំបាច់ត្រូវរាយការណ៍ទៅក្រសួងមានសមត្ថកិច្ចដ៏ត្រឹមត្រូវ ឯទៀត ឬទៅអង្គការរដ្ឋ នានា ដែលមានអំណាចសើរើត្រួតពិនិត្យ ឬដោះស្រាយ ។

អត្ថាធិប្បាយ ៖


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ក-គេត្រូវតែគោរពតាមបទវិន័យនេះភ្លាម កាលណាបទវិន័យនេះបានត្រូវគេបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។ ប៉ុន្តែនៅប្រទេសខ្លះច្បាប់នីតិបញ្ញត្តិ ឬនីតិប្រតិបត្តិរបស់គេ មានលក្ខណៈតឹងរឹងជាងបទវិន័យបច្ចុប្បន្ននេះទៅទៀត។ ក្នុងករណីបែបនេះ ភ្នាក់ងារតំរួតត្រូវតែគោរព តាមច្បាប់ដែលតឹងរឹងនោះ ។

ខ-មាត្រា ៨ នេះ សំដៅយកការថ្លឹងថ្លែងឲ្យបានសមរម្យរវាងគោលសំខាន់ពីរ គោលសំខាន់ ទី ១ គឺការរក្សានិងការពង្រឹងវិន័យផ្ទៃក្នុងរបស់ក្រសួង ដើម្បីជាប្រយោជន៍ដ៏ទូលំទូលាយដល់សន្តិសុខ សាធារណៈ។ គោលសំខាន់ទី ២ គឺការបង្ការ និងការការពារកុំឲ្យមានអំពើរំលោភលើសិទ្ធិមនុស្សជា មូលដ្ឋាន។ បើមានការរំលោភច្បាប់ ភ្នាក់ងារតំរួតត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅនាយថៅហ្វាយតាម លំដាប់លំដោយនៃឋានានុក្រម (តាមលំដាប់ថ្នាក់នៃបុណ្យសក្តិនៅក្នុងក្រសួងរបស់ខ្លួន)។ ដរាបណា ក្រសួងរបស់ខ្លួនបានប្រើគ្រប់មធ្យោបាយហើយតែគ្មានប្រសិទ្ធិភាព ដរាបនោះភ្នាក់ងារតំរួតអាចរាយ ការណ៍អំពីរឿងរំលោភច្បាប់នេះទៅក្រសួងមានសមត្ថកិច្ចដទៃទៀត។ ក្នុងការធ្វើសេចក្តីរាយការណ៍ អំពីការរំលោភលើបទវិន័យ ឬអំពីគំរោងផែនការណ៍ ដើម្បីប្រព្រឹត្តអំពើពុករលួយណាមួយអ្នករាយការណ៍ (ភ្នាក់ងារតំរួត) មិនត្រូវទទួលការចាប់កំហុស ឬការពិន័យទោសអ្វីពីក្រសួងឡើយ ។

គ-ពាក្យថា "ក្រសួងមានសមត្ថកិច្ចសមស្រប ឬអង្គការរដ្ឋដែលមានអំណាចពិនិត្យសើរើ និង ដោះស្រាយ" យោងទៅលើក្រសួង ឬអង្គការរដ្ឋដែលស្ថិតនៅក្នុងរង្វង់នៃច្បាប់របស់ជាតិ ទោះជាអង្គការ របស់ទីភ្នាក់ងារក្រសួងការពារច្បាប់ ឬជាអង្គការ ដែលមានអំណាចតាមល័ក្ខខ័ណ្ឌ អំណាចតាមទម្លាប់ ឬ អំណាចផ្សេងៗទៀត ក្នុងការពិនិត្យសើរើទៅលើសំណុំពាក្យដែលថ្លែងអំពីការរងទុក្ខទោស ឬដែលថែង អំពីបណ្តឹងតវ៉ា នានាដែលកើតមកអំពីការរំលោភបំពានច្បាប់ នៅក្នុងរង្វង់ព្រំដែននៃបទវិន័យនេះ ។

ឃ-នៅប្រទេសខ្លះ គ្រប់មធ្យោបាយនៃការផ្សព្វផ្សាយដូចជាខ្សែភាពយន្ត (កុន) ល្ខោន វិទ្យុ ទូរទស្សន៍ និងទស្សនាវដ្តី ។ល។ និង ។ល។ បានត្រូវគេចាត់ទុកថាបានបំពេញភារកិច្ច (ក្នុងការ ពិនិត្យសើរើសារឡើងវិញនូវពាក្យបណ្តឹងនានា) ប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចដែលបានពិពណ៌នា នៅក្នុងវគ្គ (គ) ខាងលើ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ង-ដើម្បីទាក់ទាញមតិសាធារណជន ឲ្យចេះឈឺឆ្អាលក្នុងរឿងរំលោភច្បាប់នេះ ភ្នាក់ងារក្រសួងការពារច្បាប់អាចផ្សព្វផ្សាយតាមរយៈវិទ្យុ, ទូរទស្សន៍, កុន, ល្ខោន, ទស្សនាវដ្តី ឬកាសែតក៏បានឲ្យ តែគេអាចបញ្ជាក់ហេតុផលថា គេបានអនុលោមទៅតាមច្បាប់ទម្លាប់របស់ប្រទេសគេ និងគោរពតាម បញ្ញត្តិនៃមាត្រាទី ៨ ក្នុងបទវិន័យនេះ ។ ប៉ុន្តែការប្រើតាមមធ្យោបាយខាងលើនេះ អាចប្រើបានតែក្នុង ដំណាក់ការចុងក្រោយបំផុតប៉ុណ្ណោះ ប្រសិនបើគ្រប់មធ្យោបាយឯទៀតដែលគេបានប្រើរួចមកហើយ នោះ ពុំបានសំរេចដូចបំណង ។

ច-ភ្នាក់ងារក្រសួងការពារច្បាប់ទាំងឡាយណា ដែលបានគោរពច្បាប់នៃបទវិន័យនេះ តែងតែបានទទួលនូវការគោរពស្ញើចសរសើរ, ការគាំទ្រ, ព្រមទាំងការរួមសហប្រតិបត្តិការពីសំណាក់សហ គមន៍, ពីសំណាក់ទីភ្នាក់ងារផ្នែកអនុវត្តន៍ច្បាប់ និងអំពីសំណាក់អ្នកដែលមានអាជីពក្នុងវិស័យប្រតិបត្តិ ច្បាប់ ។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល